# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ១៧

ដោយសារតែការជំនុំជម្រះផ្នែកទីមួយនៃសំណុំរឿង០០២ វគ្គទី២ ជិតនឹងឈានដល់ទីបញ្ចប់ អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការលើឯកសារស្តីពីភស្តុតាងពាក់ព័ន្ធទៅនឹងសហករណ៍ស្រុកត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ អង្គជំនុំជម្រះ បានកំណត់រយៈពេលសរុបចំនួនពីរថ្ងៃ សម្រាប់ភាគីទាំងអស់ដើម្បីដាក់បង្ហាញនូវឯកសារគន្លឹះទាំងឡាយណាដែលស្ថិតនៅក្នុងវិសាលភាពនេះ ហើយអង្គជំនុំជម្រះក៏បានកំណត់ថ្ងៃទីបីសម្រាប់ភាគីទាំងអស់ ក្នុងការផ្តល់នូវមតិយោបល់ជាផ្លូវការចំពោះការដាក់បង្ហាញឯកសាររបស់ភាគីដទៃទៀតផងដែរ។ ការិយាល័យសហព្រះរាជអាជ្ញា បានបង្ហាញឯកសារជាច្រើនដែលទាក់ទងទៅនឹងស្ថានភាពរស់នៅ និងធ្វើការរបស់សហករណ៍នៅទីជនបទ ការចាប់ខ្លួន និងការសួរចម្លើយក្នុងស្រុកត្រាំកក់ ការប្រព្រឹត្តចំពោះក្រុមគោលដៅនៅទីនោះ និងរចនាសម្ព័ន្ធសមត្ថកិច្ចរបស់កម្ពុជាប្រជាធិបតេយ្យ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានយកឱកាសនេះ ដើម្បីអាននូវឯកសារចំនួនប្រាំចេញពីពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលពុំមានឱកាសផ្តល់សក្ខីកម្មដោយខ្លួនពួកគាត់ផ្ទាល់។ រីឯមេធាវីការពារក្តីឲ្យលោក **នួន ជា** ក៏បានប្រើប្រាស់ឯកសារនានា ដើម្បីបញ្ជាក់ពីទឡ្ហីករណ៍ថា ខ្មែរក្រហមបានប្រើប្រាស់វិធីសាស្ត្រនៃការអប់រំកែប្រែជាជាងការដាក់ទណ្ឌកម្ម អង្គហេតុដែលបញ្ជាក់ថាមិនមានការប្រព្រឹត្តខុសគ្នារវាងក្រុមជនជាតិភាគតិច ឬក្រុមសេដ្ឋកិច្ចសង្គម ហើយនិងបញ្ជាក់ថាកម្រមានការពាក់ព័ន្ធនឹងការប្រើប្រាស់ការសួរចម្លើយ និងការទារុណកម្មអ្វីឡើយ។ ក្រុមមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** ត្រូវបានបញ្ឈប់ការដាក់បង្ហាញឯកសាររបស់ពួកគាត់ ដោយសារតែការដាក់បង្ហាញឯកសាររបស់ពួកគាត់ចាកឆ្ងាយពីវិសាលភាពនៃការជំនុំជម្រះក្តីផ្នែកទីមួយនេះ។ របាយការណ៍នេះ ធ្វើការអត្ថាធិប្បាយផងដែរពី

ព្រឹត្តិការណ៍ទាំងនោះ ហើយក្នុងនោះក៏មានការពិភាក្សាដេញដោលគ្នាជាថ្មីម្តងទៀត ជុំវិញការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ដែលបង្កើតជាបញ្ហាចម្បងពាក់ព័ន្ធនឹងផ្លូវច្បាប់ និងនីតិវិធីដែលបានកើតឡើងក្នុងបន្ទប់សវនាការ នាសប្តាហ៍នេះ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ចូហាន់ណា ហាម៉ាក គីនប៉ហ្គ (Johanna Hamark Kindborg), លៀ ហ៊ូបើ (Lea Huber), ដានៀល ម៉ាតថេស៍ (Daniel Mattes), តាយ លីណា, ហ្វីប៊ី សាប៊ីន (Phoebe Sabin), ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl) និង វង្ស ឧត្តម ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និង ការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដាសម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌ អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះបានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានា ក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University